# ៧ - រឿង អាកុហកស៊ី



Tablet Angebote

Tablets mit o2 Go Flat wählen & 240€ sparen. Jetzt mobil bestellen.

កាលពីព្រេងនាយ មានក្មេងម្នាក់នៅជាមួយម្ដាយ ចិញ្ចឹមជ្រូកកម្រៀវ ១, ដល់ជ្រូកនោះធំឡើង ក្មេងនោះចង់ស៊ីសាច់ជ្រូក ក៏និយាយនឹងម្ដាយថា «ម៉ែ ! ខ្ញុំចង់ស៊ីសាច់ជ្រូក សូមម៉ែឲ្យខ្ញុំកាប់ជ្រូកយើងនោះស៊ីផឹកស្រាទៅ ?» ។ ម្ដាយឃាត់ថា «កុំ ! ឯងស៊ីអីក៏ច្រើនម៉្លេះ ទុកវានឹងលក់យកប្រាក់កាសចាយ» ។ កូនឮម្ដាយឃាត់ដូច្នោះ ក៏នឹកតែក្នុងចិត្តចង់ស៊ីសាច់ជ្រូកតែសព្វថ្ងៃពុំមានភ្លេច ។ មានកាលមួយថ្ងៃកូននោះភ្ញាក់ឡើងពីដេក និយាយប្រាប់ម្ដាយថា «ត្បិតទេវតាប្រាប់ខ្ញុំថា មានមាសប្រាក់ច្រើនណាស់ម៉ែ សូមម៉ែជូនខ្ញុំទៅយក» ។ ម្ដាយឮកូននិយាយប្រាប់ដូច្នោះសួរថា «មាសប្រាក់នៅឯណា» ។ កូនឆ្លើយថា «ម៉ែទៅនឹងខ្ញុំចុះ បើខ្ញុំបង្គាប់ដូចម្ដេចម៉ែធ្វើតាមខ្ញុំ» កូនយកកញ្ជើនាំម្ដាយដើរទៅក្នុងព្រៃឆ្ងាយអំពីស្រុក ហើយកូនយកកញ្ជើទៅគ្របលើដី ប្រឹងសង្កត់ហើយស្រែកប្រាប់ម្ដាយថា «ម៉ែ ! ជួយសង្កត់ផង មាសប្រាក់នៅក្នុងដីនេះច្រើនណាស់ ម៉ែសង្កត់ឲ្យជាប់ចុះ ខ្ញុំនឹងទៅរកចបជីកមកជីកយកមាសប្រាក់, ម៉ែឯងនៅសង្កត់ឲ្យជាប់កុំលែង បើម៉ែលែង មាសប្រាក់និងបាត់អស់ទៅ» ឯម្ដាយឮកូនថាដូច្នោះក៏ខំសង្កត់កញ្ជើនោះឲ្យកូន, ឯកូននោះក៏រត់ត្រឡប់មកផ្ទះវិញ ចាប់ជ្រូកនោះយកមកកាប់ចម្អិនជាអាហារ បបួលអស់បងប្អូនអ្នកផ្ទះជិតខាងមកស៊ីផឹកស្រាលេងសប្បាយ ។ ម្ដាយនៅចាំកូនឯព្រៃ ទន្ទឹងពុំឃើញមកឃ្លានបាយអស់កម្លាំង រោយដៃរោយជើង របូតចេញពីលើកញ្ជើពុំឃើញមានអ្វីសោះ ។ លុះម្ដាយចាំកូនយូរពេក នឹកថាកូនបញ្ឆោតហើយ ក៏លែងកញ្ជើចោលត្រឡប់ទៅផ្ទះវិញ ឃើញកូនកំពុងតែស៊ីសាច់ជ្រូកផឹកស្រាលេងសប្បាយដូច្នោះ ក៏ខឹងនឹងកូនណាស់ ហើយនិយាយនឹងប្អូនខ្លួនថា «ត្បិតកូននោះវាខូចណាស់ ទុកចិញ្ចឹមមិនបានទេ ត្រូវឯងប្រកការុងយកទៅទម្លាក់ក្នុងទឹកសម្លាប់ទៅ» ។ ប្អូនឮដូច្នោះ សួរទៅបងថា «ដំណើរដូចម្ដេច បានជាយកកូនប្រកការុងទៅចោលក្នុងទឹកសម្លាប់ ?» ។ បងនិយាយប្រាប់ទៅប្អូនតាមដំណើរសព្វគ្រប់ថា «វាចេះបញ្ឆោតអញឲ្យទៅក្នុងព្រៃ ថាទៅយកមាសប្រាក់ ហើយឲ្យអញនៅចាំក្នុងព្រៃ លុះត្រាតែដល់ថ្ងៃឃ្លានបាយស្ទើរតែនឹងដាច់ពោះ, ឯវាមកកាប់ជ្រូក ស៊ីផឹកស្រាលេងសប្បាយ, ជ្រូកអញតែមួយទុកលក់ឲ្យគេ យកប្រាក់ចាយទេតើ » ។ ប្អូននោះក៏ទៅចាប់អាកុហកស៊ីប្រកក្នុងការុងធំ ។ ចងមាត់ការុងជាប់ល្អ ហើយលើកលីយកទៅនឹងចោលក្នុងទឹកទន្លេ, លុះទៅដល់មាត់ទន្លេអាកុហកស៊ី និយាយនឹងមាវាថា «លោកមាអាណិតខ្ញុំ ៗមុខជាស្លាប់ហើយ បើដូច្នេះសូមលោកមាអាណិតទៅយកក្បួនកុហក មកឲ្យខ្ញុំបន្តិច ត្បិតខ្ញុំស្លាប់ទៅនឹងទៅនៅឯឋានខ្មោច បើគ្មានក្បួនកុហកនឹងកុហកខ្មោចស៊ីពុំបានទេ នោះនឹងដាច់ពោះស្លាប់ » ។ ឯមាឮក្មួយអង្វរដូច្នោះ ក៏សួរទៅក្មួយវិញថា «ក្បួនកុហកនោះ ឯងទុកនៅឯណា? ។ ក្មួយប្រាប់ទៅមាថា «ខ្ញុំដាក់នៅលើធ្នឹម » ។ មាក៏ដាក់អាកុហកស៊ីទុកចោលនៅមាត់កំពង់ទឹក ហើយត្រឡប់ទៅរកក្បួននឹងយកមកឲ្យអាកុហកស៊ីវិញ ។

# Neue Domains bei STRATO

DE-Domain bis 02.08. nur 0,25€ mtl. Das Internet weiß, was du brauchst.



+1 Recommend this on Google



# PDF Editor Downloaden

PDF erstellen, bearbeiten, schützen umwandeln, verkleinern, Frei Testen


ចង់បាននូវរឿងព្រេងថ្មីៗទេ? សូមសរសេរអ៊ីមែលក្នុងប្រអប់នេះ

Email address... ចង់បាន

នាំមកជូនលោកអ្នកដោយ

